# មេរៀនទី ៤២: យ៉ាកុបបញ្ឆោតអេសាវនិងអ៊ីសាក

## លោកុប្បត្តិ ២៥:២៧-៣៤ & ២៧:១-៤០

**គោលបំណង៖** ព្រះចង់ឲ្យយើងមានភាពស្មោះត្រង់

**ខគម្ពីរចងចាំ៖** សុភាសិត ១២:២២ *"បបូរមាត់ដែលពោលពាក្យភូតភរជាទីស្អប់ខ្ពើមដល់ព្រះយេហូវ៉ា តែពួកអ្នកដែលប្រព្រឹត្តដោយពិតត្រង់ នោះជាទីគាប់ដល់ព្រះហឫទ័យទ្រង់វិញ។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

នៅពេលដែលយើងជ្រើសរើសភាពស្មោះត្រង់ហើយទុកចិត្តលើព្រះឲ្យអស់ពីចិត្ត នោះព្រះនឹងសប្បាយព្រះទ័យ ហើយទ្រង់នឹងការពារយើង។ នេះមិនមែនជារឿងងាយស្រួលនោះទេ តែវាអាចនាំយើងឲ្យមានទំនាក់ទំនងល្អជាមួយនឹងព្រះគ្រីស្ទ។ តើអ្នកធ្លាប់មានភាពមិនស្មោះត្រង់ជាមួយព្រះដែរឬទេ? ចុះជាមួយខ្លួនឯងវិញ? និងចំពោះអ្នកដទៃដែរវិញនោះ? យើងត្រូវការភាពក្លាហានដើម្បីចាកចេញពីការបោកបញ្ឆោត ហើយប្តេជ្ញាចិត្តចំពោះសេចក្តីពិត។ សូមចំណាយពេលបន្តិចដើម្បីសុំឲ្យព្រះដកភាពមិនស្មោះត្រង់របស់យើងចេញ។ សារភាពពីភាពទន់ខ្សោយរបស់អ្នកទៅកាន់ព្រះជាម្ចាស់ហើយទូលសូមកំលាំងនិងភាពស្មោះត្រង់របស់ទ្រង់សម្រាប់យើងវិញផងដែរ។

**ចំរៀង៖** ១. ចូរប្រយ័ត្ននឹងភ្នែកតូចអ្នក ២.បាបខ្ញុំរួចអស់ហើយ ៣. ខ្ញុំថ្វាយបង្គំទ្រង់

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត «និយាយពាក្យពិត»**

សូមនិយាយប្រយោគមួយ ដែលនៅចុងបញ្ចប់នៃប្រយោគនោះត្រូវនិយាយថា "*ខ្ញុំអត់កុហកទេ ឬ ខ្ញុំអត់ភរទេ*" ឧទាហរណ៍: កូនអាចនិយាយថា "ខ្ញុំបានទៅអង្គរវត្ត ខ្ញុំអត់បានកុហកទេ" ឬក៏ "ខ្ញុំធ្វើកិច្ចការផ្ទះរបស់ខ្ញុំរួចហើយ ខ្ញុំអត់បានកុហកទេ" ឬ "ខ្ញុំមើលថែបងប្អូនរបស់ខ្ញុំបានល្អ ខ្ញុំអត់បានភរទេ"។ កូនក៏អាចប្រើល្បិច ដោយកូនអាចនិយាយអ្វីដែលជារឿងពិត ឬកូនអាចនិយាយអ្វីដែលជារឿងមិនពិត។ បើវាជារឿងមិនពិត កូនត្រូវខំនិយាយយ៉ាងណា ដើម្បីឲ្យអ្នកផ្សេងជឿលើរឿងដែលកូននិយាយថាវាជារឿងពិត។ បន្ទាប់មកយើងនឹងសម្រេចចិត្តថាអ្វីដែលកូននិយាយនោះពិតឬអត់។

- តើកូនអាចប្រាប់បានទេថាអ្នកណានិយាយពិតឬនិយាយកុហក? រួចពន្យល់ចម្លើយរបស់កូន។ *(ឧទាហរណ៍៖ បាទ/ចាស ព្រោះពួកគេសើចពេលគេនិយាយមិនពិត, អត់ទេពីព្រោះអ្នកខ្លះពូកែនិយាយធ្វើឲ្យយើងជឿថាវាជារឿងពិត)*
- តើកូនមានអារម្មណ៍យ៉ាងណានៅពេលមាននរណាម្នាក់កុហកកូន? *(ចម្លើយអាចជា៖ខ្ញុំមានអារម្មណ៍ថាពួកគេមិនគោរពខ្ញុំ, ខ្ញុំខឹង, ខ្ញុំមិនទុកចិត្តម្នាក់នោះទៀតទេ)*

ពេលខ្លះវាពិបាកមើលដឹងថានរណានិយាយពិតឬនិយាយកុហកណាស់។ មនុស្សនិយាយកុហកដោយសារហេតុផលផ្សេងៗ។ តាមធម្មតាពួកគេព្យាយាមលាក់បាំងអ្វីមួយឬពួកគេខ្លាចមានបញ្ហា។ យើងមិនអាចទុកចិត្តគេបានទៀតទេ នៅពេលដែលគេបានធ្វើឲ្យយើងបាត់បង់ការទុកចិត្តលើគាត់ហើយនោះ។ ព្រះដឹងថាការទុកចិត្តគ្នាគឺសំខាន់ខ្លាំងណាស់។ កូនមិនចាំបាច់សង្ស័យទេ កូនអាចទុកចិត្តព្រះបាន ពីព្រោះទ្រង់តែងតែស្មោះត្រង់ហើយនោះមិនមែនជាការកុហកនោះទេ!

## ៤. ការណែនាំមេរៀន

តើមានអ្នកណាធ្លាប់លួចលុយឪពុកម្តាយទេ? ឬក៏ធ្លាប់និយាយកុហកប៉ាម៉ាក់ទេ? ហើយតើមានអ្នកណាធ្លាប់យករបស់មិត្តភក្តិហើយមិនសងគេវិញទេ? មនុស្សគ្រប់គ្នាតែងតែប្រឈមមុខនឹងបញ្ហាក្នុងការនិយាយការពិត ប៉ុន្តែព្រះតែងតែស្មោះត្រង់ជានិច្ច។ បើព្រះជាម្ចាស់មានបន្ទូលថាវានឹងកើតឡើងនោះវានឹងកើតឡើងពិតមែន! ប្រសិនបើព្រះជាម្ចាស់សន្យាទ្រង់នឹងរក្សាវា! ប្រសិនបើព្រះបង្រៀនអ្វីមួយតាមរយៈព្រះបន្ទូលរបស់ទ្រង់នោះវាគឺជាការពិត ដោយគ្មានការសង្ស័យឡើយ! យើងអាចជឿជាក់លើព្រះជាម្ចាស់ថាទ្រង់តែងតែស្មោះត្រង់ជានិច្ច ដែលមនុស្សមិនអាចធ្វើដូចជាទ្រង់បានទេ។ នៅក្នុងបទគម្ពីរថ្ងៃនេះ យ៉ាកុប និងអេសាវបានបង្ហាញថាមនុស្សខុសពីព្រះយ៉ាងដូចម្តេច។ មនុស្សនិយាយកុហកបោកប្រាស់អ្នកដទៃដើម្បីទទួលបានអ្វីដែលពួកគេចង់បាន។ ប៉ុន្តែព្រះមិនដែលធ្វើដូច្នេះទេ។ យើងអាចជឿជាក់បានថា ព្រះតែងតែប្រាប់ការពិតដល់យើងជានិច្ច។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

បន្ទាប់ពីអ៊ីសាករៀបការជាមួយរេបិកាពួកគេមានកូនប្រុសភ្លោះពីរនាក់គឺយ៉ាកុបនិងអេសាវ។ អេសាវជាកូនច្បងជជាកូនសំណព្វរបស់អ៊ីសាកហើយយ៉ាកុបជាកូនសំណព្វរបស់រេបិកា។ ការស្រឡាញ់កូនមិនស្មើគ្នាវាជារឿងមិនល្អនោះទេ។ ប៉ុន្តែព្រះស្រឡាញ់យើងទាំងអស់ស្មើៗគ្នា ទោះបើជាយើងប្លែកពីគ្នាក៏ដោយ!

នៅអ៊ីស្រាអែលការកើតមកជាកូនច្បងមានន័យថា ព្រះជាម្ចាស់នឹងប្រទានមរតកឲ្យកូនច្បងនោះទ្វេដង។ ថ្ងៃមួយ នៅពេលដែលអេសាវត្រលប់មកដល់ផ្ទះវិញគាត់ឃ្លានខ្លាំងណាស់ គាត់បានសុំអាហារពីយ៉ាកុប។ យ៉ាកុបបានបញ្ឆោតអេសាវ ដោយប្រាប់ឱ្យគាត់លក់សិទ្ធិជាកូនច្បងដើម្បីប្តូរយកអាហារមួយពេលនេះទៅ។ អេសាវមិនសូវជាខ្វល់ខ្វាយពីព្រះពរដែលគាត់នឹងទទួលបានពីព្រះក្នុងនាមជាកូនច្បងថាសំខាន់នោះទេ ដូច្នេះគាត់បានស្បថថា គាត់នឹងបោះបង់សិទ្ធិជាកូនច្បងដោយប្តូរជាមួយនឹងអាហារមួយចាននេះ! ព្រះមិនសប្បាយចិត្តទេនៅពេលឃើញយើងបោកប្រាស់ឬកុហកអ្នកដទៃនោះ។ យ៉ាកុបបានធ្វើរឿងដ៏អាក្រក់នៅក្នុងព្រះនេត្ររបស់ព្រះ។

ទោះបីជាអេសាវបាត់បង់សិទ្ធិជាកូនច្បងក៏ដោយ ក៏អ៊ីសាកនៅតែចង់ឲ្យពរដល់អេសាវមុនពេលគាត់ស្លាប់ ហើយអ៊ីសាកពិតជាចង់ធ្វើបែបនេះខ្លាំងណាស់។ ប៉ុន្តែរេបិកាបានកុហកគាត់ជាលើកទីពីរ ដោយនាងប្រាប់យ៉ាកុបឲ្យស្លៀកពាក់បន្លំខ្លួនជាអេសាវ ហើយទៅសុំពរពីឪពុករបស់គាត់។ ដោយសារតែអ៊ីសាកមានវ័យចំណាស់ហើយទើបភ្នែកគាត់មើលមិនសូវច្បាស់ថាម្នាក់ណាជាអេសាវ ឬ យ៉ាកុបនោះទេ។

ដើម្បីស្វែងយល់ពីរេបិកាសូមអាន(*លោកុប្បត្តិ ២៥:២៣*) ព្រះបានសន្យាថាកូនប្រុសច្បងរបស់នាងនៅពេលចាស់នឹងបំរើកូនប្អូន។ នាងប្រហែលជាគិតថានាងកំពុងជួយព្រះដោយនិយាយកុហកអ៊ីសាក! ប៉ុន្តែព្រះមិនត្រូវ

ការជំនួយរបស់យើងទេ ជាពិសេសប្រសិនបើយើងនិយាយកុហកឬបន្លំបែបនេះនោះ! ទោះជាយ៉ាងនេះក្តី រេបិកាបានជួយយ៉ាកុបបន្លំឪពុកចំណាស់របស់គាត់ដើម្បីទទួលបាននូវពរដែលបានបម្រុងសម្រាប់អេសាវរហូតទាល់តែបាន។

ការបោកប្រាស់នេះបានធ្វើឱ្យគ្រួសារមានបញ្ហា។ អេសាវបានស្បថថានឹងសម្លាប់យ៉ាកុបភ្លាមៗបន្ទាប់ពីឪពុករបស់ពួកគេបានស្លាប់ (*លោកុប្បត្តិ ២៧:៤១*)។ យ៉ាកុបត្រូវរត់ចេញពីផ្ទះ ហើយគាត់មិនបានជួបម្តាយគាត់ទៀតឡើយ។

## ៦. សំនួរពិភាក្សា

១. តើអ្នកណាជាអ្នកបោកបញ្ឆោតយកព្រះពរពីឪពុក? *យ៉ាកុប*

២. តើអ្នកណាបានរួមដៃក្នុងការបោកបញ្ឆោតនោះ? *ម្តាយរបស់គាត់ គឺរេបិកា*

៣. តើយ៉ាកុបនិងម្តាយរបស់គាត់បញ្ឆោតអ៊ីសាកដោយរបៀបណា?
*គាត់រៀបចំសំឡឲ្យឪពុក គាត់និង បន្លំខ្លួនធ្វើជាអេសាវ*

៤. តើការកុហកនោះវាជាការល្អឬអាក្រក់? *មិនល្អទេ ព្រះចង់ឲ្យយើងធ្វើនូវរឿងល្អ ត្រឹមត្រូវ ស្មោះត្រង់*

## ៧. ល្បែងកំសាន្ត «ល្អ ឬអាក្រក់»

- សរសេរ “**ការល្អ**” ឬ “**អាក្រក់**” នៅលើក្រដាសហើយបិតនៅលើជញ្ជាំង (ធ្វើយ៉ាងណាកុំឲ្យសិស្សមើលឃើញអក្សរដែលសរសេរលើក្រដាសនោះ)



- បន្ទាប់មកចាក់បទចំរៀងហើយឲ្យសិស្សរាំជុំវិញជារង្វង់នៅពេលដែលចំរៀងឈប់សិស្សត្រូវជ្រើសរើសយក ក្រដាសបិទណាមួយនៅលើជញ្ជាំងដោយដើរ ទៅឈរនៅទីតាំងដែលបានបិទក្រដាសនោះ។
- ក្រុមដែលរើសយកក្រដាសដែលសរសេរពាក្យ “**ការល្អ**” នោះជាក្រុមដែលឈ្នះ។

បន្ទាប់ពីលេងល្បែងនេះចប់សូមសួរសិស្សថា តើគេមានអារម្មណ៍យ៉ាងណាដែរនៅពេលដែលគេបានជ្រើសរើសយកផ្ទាំង “**ការល្អ**”? គ្រូត្រូវជួយរំលឹកសិស្សឲ្យដឹងថា ពួកគេត្រូវមានការប្រុងប្រយត្ន័ក្នុងការសំរេចចិត្តមុននឹងធ្វើអ្វីមួយ។

## ៨. ខគម្ពីរចងចាំ សុភាសិត ១២:២២

**ល្បែងចងចាំខគម្ពីរ:** <u>កាត់ក្រដាសជា១០ចំរៀកដូចភីហ្សា:</u> សូមជួយកុមារឲ្យចងចាំខគម្ពីរនេះ ដោយសរសេរនូវខគម្ពីរលើចំរៀកក្រដាសដែលយើងបានកាត់រួចនោះ។ បន្ទាប់មកគ្រូឲ្យកុមារទន្ទេញខគម្ពីរទៅតាមចំរៀកក្រដាសនីមួយៗ នៅពេលពួកគេទន្ទេញចប់ គ្រូត្រូវដកក្រដាសម្តង ១ ចំរៀករហូតដល់ចំរៀកទី ១០ ហើយសូមជួយឲ្យកុមារទន្ទេញខគម្ពីរចងចាំទាំងមូល។ ឲ្យកុមារបន្តទន្ទេញខគម្ពីរនោះរហូតដល់ចាំខគម្ពីរទាំងមូល។

## ៩. ហត្ថកម្ម សុភាសិត ១២:២២

**សំភារៈដែលត្រូវការ៖** ក្រដាស ខ្មៅដៃ




- សរសេរពាក្យថា “ល្អ” នៅលើក្រដាសផ្ទាំងធំមួយនិងពាក្យថា “អាក្រក់” នៅលើក្រដាសធំមួយទៀតហើយបិទនៅលើជញ្ជាំង។
- ចែកក្រដាស ២ សន្លឹកទៅឲ្យសិស្សម្នាក់ៗ ហើយឲ្យសិស្សសរសេរពាក្យ “**ល្អ**” លើក្រដាស ១សន្លឹក ហើយសរសេរពាក្យ “**អាក្រក់**” នៅលើក្រដាស ១សន្លឹកទៀត
- សួរសិស្សថា តើអ្វីខ្លះជាអំពើល្អ? ហើយឲ្យសិស្សយកក្រដាសដែលគេបានសរសេរពីសកម្មភាពដែលជាអំពើ “**ល្អ**” បិទលើក្រដាសផ្ទាំងធំ ដែលបានសរសេរពាក្យថា “**ល្អ**” ។
- ធ្វើដូចគ្នាដែរដោយឲ្យសិស្សសរសេរនៅលើក្រដាសដែលមានពាក្យថា “**អាក្រក់**”
- នៅពេលសិស្សបានបិទរួច សូមពន្យល់សិស្សថាពីព្រោះព្រះអម្ចាស់នៃយើងទ្រង់តែងតែល្អជានិច្ច យើងក៏ត្រូវព្យាយាមឲ្យអស់ពីសមត្ថភាពដើម្បីធ្វើខ្លួនឲ្យបានល្អផងដែរ។
- ឲ្យសិស្សឡើងមកបិទក្រដាសដែលពួកគេបានសរសេរទៅតាមទីកន្លែងដែលត្រឹមត្រូវម្តងម្នាក់ៗ។

(***ហត្ថកម្មៈជាជំរើស***) “អ្នកណាដែលទទួលបានព្រះពរពីព្រះ?” (សូមមើលទំព័រខាងក្រោម)

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

## អ្នកណាដែលទទួលបានព្រះពរពីព្រះ?




សូមសរសេរខគម្ពីរចងចាំ: ______________________________

______________________________________________

______________________________________________

______________________________________________